ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ : ...............................

# កំណត់ហេតុកិច្ចប្រជុំ
## ស្តីពីការត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការពង្រឹងការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែវិច្ឆិកា ថ្ងៃទីប្រាំពីរ វេលាម៉ោងប្រាំបួនព្រឹក នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានបើកកិច្ចប្រជុំពិភាក្សាស្តីពីការត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការពង្រឹងការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ** ។

សមាសភាពចូលរួមកិច្ចប្រជុំសរុបចំនួន ១៥រូប រួមមានតំណាង អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងការងារ ក្រសួងសង្គមកិច្ច និងក្រសួងការបរទេស ។

គោលបំណងនៃកិច្ចប្រជុំគឺ ដើម្បីពិភាក្សានូវចំណុចពាសំខាន់សម្រាប់ជាប្រធានបទនៃសិក្ខាសាលារួមមាន ការផ្តល់សំណងដល់ជនរងគ្រោះ នីតិវិធីជំនួយផ្នែកច្បាប់ និងការផ្តល់ទីកន្លែងសម្រាប់ប្រព្រឹត្តអំពើជួញដូរមនុស្ស ព្រមទាំងរកនូវចំណុចសំខាន់ៗ បន្ថែមទៀតសម្រាប់ដាក់ចូលក្នុងសិក្ខាសាលាថ្នាក់ជាតិ ដែលនឹងប្រព្រឹត្តទៅក្នុងពេលឆាប់ៗនេះ ។

**ក. មតិតំណាងក្រសួងពាក់ព័ន្ធ**

**លោក អ៊ុក វ៉ាវុធ តំណាងក្រសួងការងារ បានលើកឡើងថា៖**

- តាំងពីឆ្នាំ២០០១មក ពលករតាមក្រុមហ៊ុនប្រហែល ៨ពាន់នាក់ បានផុតអាណត្តិហើយ តែបើពួកគាត់មានបញ្ហា ក្រសួងការងារនឹងទំនាក់ទំនងជាមួយក្រុមហ៊ុនដើម្បីសម្របសម្រួលដោះស្រាយ ។
- ពលករដែលផុតអាណត្តិត្រូវត្រឡប់មកកម្ពុជាវិញសិន ហើយក្រុមហ៊ុនដែលមិនបានជូនដំណឹងអំពីពលករផុតអាណត្តិមកក្រសួងការងារ នឹងត្រូវបានដកប្រាក់កក់ ។
- សព្វថ្ងៃពលករពន្យារតាមស្ថានទូត បើស្ថានទូតមិនពន្យារឲ្យក៏មិនអាចបន្តការងារដែរ ។
- នៅក្នុងMOU ពេលបញ្ជូនមកវិញក្រុមហ៊ុនត្រូវមានការឯកភាពពីស្ថានទូត មិនមែនបញ្ជូនមកដោយផ្ទាល់ដូចមុនទេ ។ ស្ថានទូតមានសិទ្ធិអាចឆែកគណនីរបស់ពលកររបស់ក្រុមហ៊ុន ។

**លោក អ៊ឹង វណ្ណថា តំណាងក្រសួងការបរទេស បានលើកឡើងថា៖**

- ការពន្យារលិខិតឆ្លងដែននៅក្រៅប្រទេស ពេលខ្លះពួកគាត់មានគ្រួសារទូរស័ព្ទទៅជានា យំសោក និងមានសមាគមន៍ជួយ ។ ឬពួកគាត់មកពន្យារនៅកម្ពុជាពេលមកលេងស្រុក រួចត្រឡប់ទៅធ្វើការវិញ ។ កន្លងមកបញ្ហាមានច្រើនតែចំពោះអ្នកដែលរត់ពីកន្លែងមួយទៅកន្លែងមួយ ។

- បញ្ហាសំខាន់មួយទៀតគឺនៅត្រង់ថា យើងមិនដឹងថាពលករ-ពលការិនីយើងនៅគេប៉ុន្មាន ដូចនេះត្រូវជំរុញក្រុមហ៊ុនធ្វើឲ្យច្បាស់ ។

ខ. សមាសភាពដែលត្រូវអញ្ជើញចូលរួមសិក្ខាសាលាថ្នាក់ជាតិ ៖

- អគ្គស្នងការដ្ឋាននគរបាលជាតិ ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋានកណ្តាលយុត្តិធម៌ ស្នងការ-ស្នងការរាជធានី-ខេត្ត
- អគ្គនាយកដ្ឋានអន្តោប្រវេសន៍
- អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
- កងរាជអាវុធហត្ថ
- ស្ថាប័នតុលាការ ៖ ចៅក្រម និង ស្ថាប័នអយ្យការ ៖ ព្រះរាជអាជ្ញា
- ក្រសួងសង្គមកិច្ច ៖ មន្ទីរសង្គមរាជធានី និងខេត្តជាប់ព្រំដែន
- ក្រសួងការងារ ៖ ពី៥ទៅ១០នាក់មាន ថ្នាក់ក្រសួង ថ្នាក់ខេត្ត និងអគ្គនាយកបច្ចេកទេស
- ក្រសួងការបរទេស ៖ ចង់ឲ្យស្ថានទូតខ្មែរនៅបរទេសចូលរួម (កន្លងមកស្ថានទូតខ្មែរនៅម៉ាឡេស៊ី និងថៃចូលរួម តែក្រោយមកក្រសួងជាអ្នកចូលរួម រួចយកណែនាំបន្ត)
- ក្រសួងកិច្ចការនារី ៖ ពាក់ព័ន្ធខាងបណ្តឹងច្រើនករណីជួញដូរផ្លូវភេទ
- សមាគមន៍ក្រុមហ៊ុនបញ្ជូនពលករ ៖ និយោជក និងខាងសមាគមន៍ (ក្រុមហ៊ុនទាំងអស់មានជាង៦០ តែកំពុងដំណើរការមានតែជាង៣០ទេ)

គ. ស្ថាប័នពាក់ព័ន្ធ ឬត្រូវឡើងធ្វើបទបង្ហាញនៃប្រធានបទនីមួយៗ៖

១.នីតិវិធីជួយជនរងគ្រោះទទួលបានយុត្តិធម៌ និងសំណងពីជនល្មើស (ការផ្តន្ទាទោស និងសំណង) ដែលស្ថាប័នពាក់ព័ន្ធមាន អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងយុត្តិធម៌ ក្រសួងការបរទេស និងក្រសួងការងារ(នីតិវិធីដោះស្រាយបណ្តឹង) ។

២.ការពង្រឹងអនុវត្តនីតិវិធីច្បាប់ជួយជនរងគ្រោះនៅក្រៅប្រទេសតាមរយៈអាជ្ញាធរកណ្តាល ដែលស្ថាប័នពាក់ព័ន្ធមាន នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ក្រសួងយុត្តិធម៌ ក្រសួងការបរទេស និងអង្គការ ។

៣.ការផ្តល់ទីកន្លែងសម្រាប់ប្រព្រឹត្តអំពើជួញដូរមនុស្ស ដែលស្ថាប័នពាក់ព័ន្ធមាន អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងយុត្តិធម៌

ជាទីបញ្ចប់ លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ បានមានប្រសាសន៍ណែនាំអំពីការងារមួយចំនួនដូចខាងក្រោម៖

- បើមាននីតិវិធីច្បាប់គ្រប់គ្រាន់ហើយតែខ្វះការអនុវត្ត នោះយើងត្រូវធ្វើការជំរុញ ។
- បើនៅក្នុងMOUមានហើយតែប្រទេសគោលដៅមិនអនុវត្ត យើងត្រូវលើកឡើង ។
- ត្រូវត្រៀមលក្ខណៈរកចំណុច គន្លឹះសំខាន់ៗ និងទិន្នន័យ ។
- អ្នកចូលរួមអាចចែកជាក្រុមដើម្បីឡើងធ្វើបទបង្ហាញ ដែលមានរយៈពេលប្រហែល១៥នាទីនិយាយពីបទពិសោធន៍ បញ្ហាប្រឈម និងសំណូមពរដោះស្រាយ ។
- សិក្ខាសាលានេះត្រូវនិយាយពីអ្វីដែលអាចធ្វើបាន និងធ្វើមិនបាន ដើម្បីឲ្យដឹងថាយើងបានឈានដល់កម្រិតណាហើយ ។

- ថ្នាក់ក្រសួងនិយាយក៏បាន ថ្នាក់ខេត្តនិយាយក៏បាន ឲ្យតែគោលដៅ ។

- ពេលវេលាបើកអង្គសិក្ខាសាលាគឺសំខាន់លើតើយើងត្រៀមកិច្ចការហើយឬនៅ ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី២៤ ខែ វិច្ឆិកា ឆ្នាំ២០១៦

**អ្នកកត់ត្រា**

គោរពជូន លោកជំទាវ

អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០១៦

**ប្រធានលេខាធិការដ្ឋាន**

ឧត្តមសេនីយ៍ត្រី គង់ . វុទ្ធី

**សមាសភាពចូលរួមកិច្ចប្រជុំ**
**ស្តីពីការត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការពង្រឹងការអនុវត្តច្បាប់**
**និងប្រព័ន្ធយុត្តិធម៌ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស**
**ថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១៦**
**សរុបចំនួន ១៥ រូប**

| | | | | |
|---|---|---|---|---|
| ១ | - លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការ | អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ |
| ២ | - ឯកឧត្តម ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ | គ.ជ.ប.ជ |
| ៣ | - ឯកឧត្តម ឧ.ឯក | ស៊ុន រ៉ូ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៤ | - ឯកឧត្តម ឧ.ឯក | យឹម វិរៈ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៥ | - លោកជំទាវ ឧ.ឯក | ប៊ុណ្ណ សំខាន់ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| ៦ | - ឧត្តមសេនីយ៍ត្រី | កែប សារឿន | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| ៧ | - ឧត្តមសេនីយ៍ត្រី | គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋានស្តីទី | គ.ជ.ប.ជ |
| ៨ | - ឯកឧត្តម | សូរ ឌីម៉ា | អនុប្រធានក្រុមប្រឹក្សានីតិកម្ម | ក្រុមប្រឹក្សានីតិកម្ម |
| ៩ | - ឯកឧត្តម | ពេញ វិបុល | ព្រះរាជអាជ្ញា និងជាអគ្គនាយករង | ក្រសួងយុត្តិធម៌ |
| ១០ | - លោកស្រី | កែវ ម៉ាលី | អនុប្រធាននាយកដ្ឋាន | ក្រសួងសង្គមកិច្ច |
| ១១ | - លោក | អ៊ឹង វណ្ណថា | អនុប្រធាននាយកដ្ឋាន | ក្រសួងការបរទេស |
| ១២ | - ឧត្តមសេនីយ៍ទោ | ប៉ាក់ យូលាង | អនុប្រធាននាយកដ្ឋាន | នា.ប្រឆាំងការជួញដូរមនុស្ស |
| ១៣ | - ឧត្តមសេនីយ៍ត្រី | លី ឡាយ | អនុប្រធាននាយកដ្ឋាន | នា.ប្រឆាំងការជួញដូរមនុស្ស |
| ១៤ | - លោក | អ៊ុក វ៉ារុធ | ប្រធានការិយាល័យ | ក្រសួងការងារ |
| ១៥ | - អនុសេនីយ៍ឯក | ហ៊ី រតនៈ | នាយរងការិយាល័យ | គ.ជ.ប.ជ |